ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ........ សហវ ......

ថ្ងៃ ........ ខែ ........ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ........ ខែ ........ ឆ្នាំ២០២១

# ជម្រាបជូន
## ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**កម្មវត្ថុ៖** ករណីសំណើសុំអនុញ្ញាតជាគោលការណ៍ប្រគល់សិទ្ធិជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យនិងសម្រេចផ្តល់ទិដ្ឋាការលើមុខសញ្ញាចំណាយមួយចំនួនពាក់ព័ន្ធនឹងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគព្រៀសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្ត និងសាលាអនុវត្តន៍ ចាប់ពីឆ្នាំ ២០២១ តទៅ ។

**យោង៖** លិខិតលេខ៩៧៤ អយក.ហវ ចុះថ្ងៃទី០៩-០៣-២០២១ របស់ក្រសួងអប់រំ យុវជន និងកីឡា

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានពិនិត្យនិងសម្រេចដូចខាងក្រោម ៖

១- ត្រូវអនុវត្តតាមនីតិវិធី និងបរិបថនៃការអនុវត្តថវិកាដែលមានជាធរមាន ចំពោះការពិនិត្យដើម្បីបើកផ្តល់សាច់ប្រាក់សម្រាប់ដំណើរការរបស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ រួមមាន មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគព្រៀសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្ត និងសាលាអនុវត្តន៍ ។

២- ប្រគល់សិទ្ធិបន្ថែមជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យនិងចុះហត្ថលេខា លើមុខសញ្ញាចំណាយដូចខាងក្រោម ៖

- ថវិកាប្រជុំប្រចាំសប្តាហ៍របស់សាលាមត្តេយ្យសិក្សាអនុវត្តន៍
- ថវិកាប្រជុំបច្ចេកទេសថ្ងៃព្រហស្បតិ៍របស់សាលាបឋមសិក្សាអនុវត្តន៍
- ថវិកាប្រជុំតាមកម្រងសាលារៀនរបស់សាលាបឋមសិក្សាអនុវត្តន៍
- ថវិកាប្រជុំប្រចាំខែរបស់សាលាមធ្យមសិក្សាចំណេះទូទៅអនុវត្តន៍
- ថវិកាអាហារូបករណ៍សិស្សក្រីក្រជួបការលំបាករបស់សាលាអនុវត្តន៍



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- ថវិកាអាហារូបករណ៍គរុសិស្សដែលកំពុងសិក្សានៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ
- រង្វាន់សិស្សពូកែរបស់សាលាអនុវត្តន៍
- ថវិកាបំប៉នគ្រូបង្រៀនកម្រិតបឋមដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន នៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ
- ថវិកាសម្រាប់សាងសង់បង្គន់អនាម័យនិងប្រព័ន្ធទឹកស្អាតរបស់សាលាអនុវត្តន៍ ។

៣- ទន្ទឹមនឹងនេះ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវពិនិត្យនិងវាយតម្លៃគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ (មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគព្រៀសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្ត ) ដើម្បីក្លាយជាអង្គភាពថវិកា និងផ្តល់សិទ្ធអំណាចជូនគ្រឹះស្ថានទាំងនោះក្នុងការអនុវត្តថវិកា ក៏ដូចជា ពន្លឿនដល់ការអនុវត្តថវិកាផងដែរ ។

សេចក្តីដូចបានជម្រាបជូនខាងលើនេះ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ** មេត្តាជ្រាប និងចាត់ចែងតាមការគួរ ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ទទួលនូវគារវកិច្ចពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>ចម្លងជូន ÷</u>**

-អគ្គនាយកដ្ឋានរតនាគារជាតិ

-ឯកសារ-កាលប្បវត្តិ